**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:..០០១/..១៧..ស្ន.ន.១..គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវា ក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញប្រកាសលេខ ០០៨/១១ គមក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- បានឃើញសំណើសុំកែប្រែថ្លៃសេវាប្រតិបត្តិការ និងសេវាចុះបញ្ជីលក់មូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជាលើកទី២៤ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងប្រការ ២២ នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធប្រកាសលេខ ០០៨/១១ គមក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែមេសាឆ្នាំ២០១២

គាត ឈន់

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០០១/១២ ស៊ុន១.ក.ម.ក
ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

ស្តីពី

# ការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ប្រការ ២២ ថ្មី.-**

បុគ្គលស្នើសុំការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាចំនួន ៤.០០០.០០០ (បួនលាន) រៀលជូន **ផ.ម.ក.**។

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាសម្រាប់ការចុះបញ្ជីមូលបត្រជូន **ផ.ម.ក.** ដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់លើកដំបូងខាងក្រោម÷

១. ប្រសិនបើមូលធនូបនីយកម្មទីផ្សារតិចជាង ឬស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ១០.០០០.០០០ (ដប់លាន) រៀល។

២. ប្រសិនបើមូលធនូបនីយកម្មទីផ្សារច្រើនជាង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ប៉ុន្តែតិចជាង ឬស្មើនឹង ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម÷

ក. ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់មូលធនូបនីយកម្មទីផ្សារ ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល។

ខ. និង ០,០៤% (សូន្យក្បៀសសូន្យបួនភាគរយ) សម្រាប់មូលធនូបនីយកម្មទីផ្សារនៅសល់។

៣. ប្រសិនបើមូលធនូបនីយកម្មទីផ្សារច្រើនជាង ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល ប៉ុន្តែតិចជាង ឬស្មើនឹង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម÷

ក. ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់មូលធនូបនីយកម្មទីផ្សារ ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល។

ខ. ០,០៤% (សូន្យក្បៀសសូន្យបួនភាគរយ) សម្រាប់មូលធនូបនីយកម្មទីផ្សារ ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន) រៀល។

គ. និង ០,០៣% (សូន្យក្បៀសសូន្យបីភាគរយ) សម្រាប់មូលធនូបនីកម្មទីផ្សារនៅសល់។

៤. ប្រសិនបើមូលធនូបនីយកម្មទីផ្សារច្រើនជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល ប៉ុន្តែតិចជាង ឬស្មើនឹង ៤០០.០០០.០០០.០០០ (បួនរយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម÷

ក. ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់មូលធនូបនីយកម្មទីផ្សារ ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល។

ខ. ០,០៤% (សូន្យក្បៀសសូន្យបួនភាគរយ) សម្រាប់មូលធនទូបនីយកម្មទីផ្សារ ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន) រៀល។

គ. ០,០៣% (សូន្យក្បៀសសូន្យបីភាគរយ) សម្រាប់មូលធនទូបនីកម្មទីផ្សារ ១៦០.០០០.០០០.០០០ (មួយរយហុកសិបពាន់លាន) រៀល។

ឃ. និង ០,០២% (សូន្យក្បៀសសូន្យពីរភាគរយ) សម្រាប់មូលធនទូបនីកម្មទីផ្សារនៅសល់។

៥. ប្រសិនបើមូលធនទូបនីយកម្មទីផ្សារច្រើនជាង ៤០០.០០០.០០០.០០០ (បួនរយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម÷

ក. ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់មូលធនទូបនីយកម្មទីផ្សារ ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល។

ខ. ០,០៤% (សូន្យក្បៀសសូន្យបួនភាគរយ) សម្រាប់មូលធនទូបនីយកម្មទីផ្សារ ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន) រៀល។

គ. ០,០៣% (សូន្យក្បៀសសូន្យបីភាគរយ) សម្រាប់មូលធនទូបនីកម្មទីផ្សារ ១៦០.០០០.០០០.០០០ (មួយរយហុកសិបពាន់លាន) រៀល។

ឃ. ០,០២% (សូន្យក្បៀសសូន្យពីរភាគរយ) សម្រាប់មូលធនទូបនីកម្មទីផ្សារ ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល។

ង. និង ០,០១% (សូន្យក្បៀសសូន្យមួយភាគរយ) សម្រាប់មូលធនទូបនីកម្មទីផ្សារនៅសល់។